STATE OF CALIFORNIA
DMV
Department of Motor Vehicles

# កិច្ចដំណើរការអនុញ្ញាតលើការផ្ទៀងផ្ទាត់

ជាផ្នែកមួយនៃការដាក់ពាក្យសុំប័ណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណ ឯកសារអន្តោប្រវេសន៍របស់អ្នកត្រូវបានផ្ទៀងផ្ទាត់តាមប្រព័ន្ធអេឡិចត្រូនិចជាមួយនឹងក្រសួងសន្តិសុខមាតុភូមិ (*Department of Homeland Security,* DHS) សេវាអន្តោប្រវេសន៍ និងពលរដ្ឋអាមេរិក (*U.S. Citizenship and Immigration Services,* USCIS)។ ឯកសាររបស់អ្នកមិនអាចផ្ទៀងផ្ទាត់បានទេ និងតម្រូវឲ្យមានការត្រួតពិនិត្យបន្ថែមទៀត។ នេះជាផ្នែកដ៏សំខាន់មួយនៃកិច្ចដំណើរការផ្ទៀងផ្ទាត់នេះ មុនពេលប័ណ្ណបើកបរ/អត្តសញ្ញាណប័ណ្ណណាមួយត្រូវបានផ្តល់ជូន និងមិនបង្ហាញថាមានបញ្ហាអ្វីមួយកើតមាន។ ការអនុញ្ញាតរបស់អ្នក គឺត្រូវការជាចាំបាច់ មុនពេល DMV អាចខំប្រឹងបញ្ចប់កិច្ចដំណើរការផ្ទៀងផ្ទាត់ឯកសាររបស់អ្នកបាន។ DMV ប្រើប្រាស់ព័ត៌មាននេះដើម្បីកំណត់សិទ្ធិទទួលបានប័ណ្ណបើកបរ/អត្តសញ្ញាណប័ណ្ណរបស់អ្នកតែប៉ុណ្ណោះ។ ការអនុញ្ញាតនេះ មានសុពលភាពត្រឹមតែមួយឆ្នាំតែប៉ុណ្ណោះចាប់ពីពេលនេះតទៅ។

**Q:** ហេតុអ្វីបានជាខ្ញុំត្រូវទទួលបានទម្រង់បែបបទអនុញ្ញាតលើការផ្ទៀងផ្ទាត់ (***Verification Authorization,* DL 93**)?

**A**: DMV មិនមានព័ត៌មានអំពីមូលហេតុដែល USCIS មិនអាចធ្វើការផ្ទៀងផ្ទាត់លើឯកសារអន្តោប្រវេសន៍របស់អ្នកបានតាមប្រព័ន្ធអេឡិចត្រូនិកនោះទេ។ ជួនកាលព័ត៌មាននេះ អាចចូលទៅប្រើប្រាស់បានតាមប្រព័ន្ធអេឡិចត្រូនិក និងអាចតម្រូវឲ្យធ្វើការស្រាវជ្រាវរកដោយដៃបន្ថែមទៀតដោយ USCIS។ ករណីផ្សេងទៀតមានកំហុសលើការវាយតួអក្សរ ឬការបាត់ព័ត៌មាននៅក្នុងសំណុំឯកសារ ឬភាពយឺតយ៉ាវរបស់ពួកគេនៅក្នុងការអាប់ឡូតទិន្នន័យបញ្ជាក់អត្តសញ្ញាណ។ គេអាចតម្រូវឲ្យ DMV ប្រគល់សំណៅថតចម្លងមួយច្បាប់នៃឯកសារអន្តោប្រវេសន៍របស់អ្នកដែលបានស្កេនរួចហើយ ដើម្បីឲ្យ USCIS អាចធ្វើការផ្ទៀងផ្ទាត់ព័ត៌មានរបស់អ្នកបាន។

**Q:** ហេតុអ្វីបានជាត្រូវធ្វើការផ្ទៀងផ្ទាត់ឯកសារអន្តោប្រវេសន៍របស់ខ្ញុំ?

**A:** អ្នកបានផ្តល់ឯកសារអន្តោប្រវេសន៍ណាមួយដើម្បីបង្ហាញថាវត្តមានរបស់អ្នក គឺទទួលការអនុញ្ញាតដោយច្បាប់សហព័ន្ធ។ DMV ធ្វើការផ្ទៀងផ្ទាត់ឯកសារទាំងអស់ ដែលអ្នកដាក់ពាក្យសុំបានផ្តល់ជូនដើម្បីបញ្ជាក់អំពីស្ថានភាពអន្តោប្រវេសន៍របស់ពួកគេ។ ដើម្បីទទួលបានប័ណ្ណបើកបរ/អត្តសញ្ញាណប័ណ្ណស្របទៅតាមច្បាប់ REAL ID របស់សហព័ន្ធ ដែលអាចប្រើប្រាស់ដើម្បីជិះយន្តហោះក្នុងស្រុក ឬចូលទៅក្នុងអគារសន្តិសុខសហព័ន្ធណាមួយ ដែលតម្រូវឲ្យមានឯកសារបញ្ជាក់អត្តសញ្ញាណ ដូច្នេះវត្តមានរបស់អ្នកដែលទទួលបានការអនុញ្ញាតនៅក្នុងសហរដ្ឋអាមេរិក ត្រូវតែធ្វើការផ្ទៀងផ្ទាត់ដោយរដ្ឋាភិបាលសហព័ន្ធ។ ព័ត៌មាននេះ នឹងត្រូវបានប្រើប្រាស់ដើម្បីកំណត់សិទ្ធិទទួលបានប័ណ្ណបើកបរ/អត្តសញ្ញាណប័ណ្ណរបស់អ្នកតែប៉ុណ្ណោះ។



STATE OF CALIFORNIA
DMV
Department of Motor Vehicles

# កិច្ចដំណើរការអនុញ្ញាតលើការផ្ទៀងផ្ទាត់

ជាផ្នែកមួយនៃការដាក់ពាក្យសុំប័ណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណ ឯកសារអន្តោប្រវេសន៍របស់អ្នកត្រូវបានផ្ទៀងផ្ទាត់តាមប្រព័ន្ធអេឡិចត្រូនិចជាមួយនឹងក្រសួងសន្តិសុខមាតុភូមិ (*Department of Homeland Security,* DHS) សេវាអន្តោប្រវេសន៍ និងពលរដ្ឋអាមេរិក (*U.S. Citizenship and Immigration Services,* USCIS)។ ឯកសាររបស់អ្នកមិនអាចផ្ទៀងផ្ទាត់បានទេ និងតម្រូវឲ្យមានការត្រួតពិនិត្យបន្ថែមទៀត។ នេះជាផ្នែកដ៏សំខាន់មួយនៃកិច្ចដំណើរការផ្ទៀងផ្ទាត់នេះ មុនពេលប័ណ្ណបើកបរ/អត្តសញ្ញាណប័ណ្ណណាមួយត្រូវបានផ្តល់ជូន និងមិនបង្ហាញថាមានបញ្ហាអ្វីមួយកើតមាន។ ការអនុញ្ញាតរបស់អ្នក គឺត្រូវការជាចាំបាច់ មុនពេល DMV អាចខំប្រឹងបញ្ចប់កិច្ចដំណើរការផ្ទៀងផ្ទាត់ឯកសាររបស់អ្នកបាន។ DMV ប្រើប្រាស់ព័ត៌មាននេះដើម្បីកំណត់សិទ្ធិទទួលបានប័ណ្ណបើកបរ/អត្តសញ្ញាណប័ណ្ណរបស់អ្នកតែប៉ុណ្ណោះ។ ការអនុញ្ញាតនេះ មានសុពលភាពត្រឹមតែមួយឆ្នាំតែប៉ុណ្ណោះចាប់ពីពេលនេះតទៅ។

**Q:** ហេតុអ្វីបានជាខ្ញុំត្រូវទទួលបានទម្រង់បែបបទអនុញ្ញាតលើការផ្ទៀងផ្ទាត់ (***Verification Authorization,* DL 93**)?

**A**: DMV មិនមានព័ត៌មានអំពីមូលហេតុដែល USCIS មិនអាចធ្វើការផ្ទៀងផ្ទាត់លើឯកសារអន្តោប្រវេសន៍របស់អ្នកបានតាមប្រព័ន្ធអេឡិចត្រូនិកនោះទេ។ ជួនកាលព័ត៌មាននេះ អាចចូលទៅប្រើប្រាស់បានតាមប្រព័ន្ធអេឡិចត្រូនិក និងអាចតម្រូវឲ្យធ្វើការស្រាវជ្រាវរកដោយដៃបន្ថែមទៀតដោយ USCIS។ ករណីផ្សេងទៀតមានកំហុសលើការវាយតួអក្សរ ឬការបាត់ព័ត៌មាននៅក្នុងសំណុំឯកសារ ឬភាពយឺតយ៉ាវរបស់ពួកគេនៅក្នុងការអាប់ឡូតទិន្នន័យបញ្ជាក់អត្តសញ្ញាណ។ គេអាចតម្រូវឲ្យ DMV ប្រគល់សំណៅថតចម្លងមួយច្បាប់នៃឯកសារអន្តោប្រវេសន៍របស់អ្នកដែលបានស្កេនរួចហើយ ដើម្បីឲ្យ USCIS អាចធ្វើការផ្ទៀងផ្ទាត់ព័ត៌មានរបស់អ្នកបាន។

**Q:** ហេតុអ្វីបានជាត្រូវធ្វើការផ្ទៀងផ្ទាត់ឯកសារអន្តោប្រវេសន៍របស់ខ្ញុំ?

**A:** អ្នកបានផ្តល់ឯកសារអន្តោប្រវេសន៍ណាមួយដើម្បីបង្ហាញថាវត្តមានរបស់អ្នក គឺទទួលការអនុញ្ញាតដោយច្បាប់សហព័ន្ធ។ DMV ធ្វើការផ្ទៀងផ្ទាត់ឯកសារទាំងអស់ ដែលអ្នកដាក់ពាក្យសុំបានផ្តល់ជូនដើម្បីបញ្ជាក់អំពីស្ថានភាពអន្តោប្រវេសន៍របស់ពួកគេ។ ដើម្បីទទួលបានប័ណ្ណបើកបរ/អត្តសញ្ញាណប័ណ្ណស្របទៅតាមច្បាប់ REAL ID របស់សហព័ន្ធ ដែលអាចប្រើប្រាស់ដើម្បីជិះយន្តហោះក្នុងស្រុក ឬចូលទៅក្នុងអគារសន្តិសុខសហព័ន្ធណាមួយ ដែលតម្រូវឲ្យមានឯកសារបញ្ជាក់អត្តសញ្ញាណ ដូច្នេះវត្តមានរបស់អ្នកដែលទទួលបានការអនុញ្ញាតនៅក្នុងសហរដ្ឋអាមេរិក ត្រូវតែធ្វើការផ្ទៀងផ្ទាត់ដោយរដ្ឋាភិបាលសហព័ន្ធ។ ព័ត៌មាននេះ នឹងត្រូវបានប្រើប្រាស់ដើម្បីកំណត់សិទ្ធិទទួលបានប័ណ្ណបើកបរ/អត្តសញ្ញាណប័ណ្ណរបស់អ្នកតែប៉ុណ្ណោះ។

បោះពុម្ព

DL 94 KM (REV. 7/2025) **WWW**